**ឯកសារស្រាវជ្រាវសង្ខេប**

អគ្គលេខាធិការ នៃព្រឹទ្ធសភា

# ការធានាកិច្ចការពារជ័យូរអង្វែងប្រឆាំងទៅនឹងការបំផ្លិចបំផ្លាញ និងការធ្វើអោយធ្លាក់ចុះនូវបេតិកភ័ណ្ឌវប្បធម៌រូបី និងអរូបីនៃមនុស្សជាតិ


ស្រាវជ្រាវដោយ៖ លោក **សេត សួនវិសាល**

លោកស្រី **ជា ម៉ាលីកា**

ដោយមានការចូលរួមពី៖ កញ្ញា **ជា សុគន្ធមិនា**

ដឹកនាំដោយ៖ លោក **ហ្វីស័រ រាជស៊ី រ៉ាណូ**



ខែកញ្ញា ឆ្នាំ ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


បេតិកភ័ណ្ឌវប្បធម៌រូបី និងអរូបីនៃប្រទេសកម្ពុជា ........................................ 1

កិច្ចការពារប្រឆាំងនឹងការបំផ្លាញ និងការធ្វើឲ្យធ្លាក់ចុះឲ្យនៃបេតិកភ័ណ្ឌរូបី និងអរូបីរបស់មនុស្សជាតិ. 3

សេចក្ដីសន្និដ្ឋាន ........................................ 6

ឯកសារយោង........................................ 8

ឧបសម្ព័ន្ធ ........................................ 9

# បេតិកភ័ណ្ឌវប្បធម៌រូបី និងអរូបីនៃប្រទេសកម្ពុជា

*បេតិកភ័ណ្ឌវប្បធម៌គឺជា វត្ថុបុរាណដែលមានលក្ខណៈរូបវ័ន្ត(រូបី) និងអរូបីរបស់ក្រុមមួយ ឬសង្គមមួយដែលបុព្វបុរសជំនាន់មុនបានបន្សល់ទុកអោយ ដែលបច្ចុប្បន្នកំពុងត្រូវបានថែរក្សា និងគោរព ដើម្បីទុកអោយកូនចៅជំនាន់ក្រោយ។*[1]

ប្រទេសកម្ពុជាសំបូរទៅដោយបេតិកភ័ណ្ឌវប្បធម៌ ″រូបី″ [2] និង ″អរូបី″ [3]។ តំបន់អង្គរដែលជាបេតិកភ័ណ្ឌពិភពលោករួមមានឧទ្យានបុរាណ ដូចជា អង្គរ រលួស និងបន្ទាយស្រី ជាតំបន់បេតិកភណ្ឌមានតម្លៃឧត្តុង្គ-ឧត្តម ដែលមានផ្ទៃដី ៤០0គីឡូម៉ែត្រការ៉េ លាតសន្ធឹងនៅលើដីទំនាបនៃប្រទេសកម្ពុជា ពីភ្នំគូលែននៅភាគខាងជើង និងបឹងទន្លេសាបនៅភាគខាងត្បូង។[4] កេរ្ត៏ដំណែលពីអាណាចក្រអង្គរគឺតំបន់បុរាណ និងវប្បធម៌ ជាតំបន់ដែលមានសារៈសំខាន់បំផុតរបស់ប្រទេសកម្ពុជា ក៏ដូចជាតំបន់ទេសចរណ៍ដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍។[5] ចំនួនភ្ញៀវទេសចរណ៍ដែលមកទស្សនាប្រាសាទអង្គរវត្តសម្រាប់ឆមាសដំបូងឆ្នាំ២០១៥ មានច្រើនលើសពី១.២៣លាននាក់ ដែលអាចរកចំណូលបានរហូតដល់ទៅ៣៥លានដុល្លារអាមេរិក។[6] ប៉ុន្តែ ចំនួនភ្ញៀវទេសចរណ៍ដ៏ច្រើនលើសលប់ទាំងនេះក៏អាចប៉ះពាល់ដល់ប្រាសាទបុរាណផងដែរ។ ដូចបានឃើញ នៅក្នុងអនុសញ្ញាកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ និងធម្មជាតិពិភពលោក «វិស័យទេសចរណ៍នាំអោយមានសក្តានុពលសេដ្ឋកិច្ចដ៏ធំសម្បើមមួយ ប៉ុន្តែវិស័យនេះក៏អាចនាំមកនូវការបំផ្លាញដែលមិនអាចស្រោចស្រង់បានចំពោះបេតិកភ័ណ្ឌរូបី និងអរូបីផងដែរ»។[7]

---

[1] UNESCO, ‘‘Tangible Cultural Heritage’’, accessed on September 1, 2015, URL: http://www.unesco.org/new/en/cairo/culture/tangible-cultural-heritage/

[2] Tangible heritage includes buildings and historical places, monuments, artifacts, etc., which are considered worthy of preservation for the future. These include objects significant to the archaeology, architecture, science or technology of a specific culture.

[3] Intangible heritage refers to the contemporary rural and urban practices in which diverse cultural groups take part such as anything that represents traditional practices, contemporary and living at the same time.3 Intangible heritage can be: inclusive, meaning it can have similarities to settlements in the geographical proximity; representative of cultural or community values and identity.

[4] UNESCO, ‘‘World Heritage’’, accessed on September 10, 2015, URL: http://whc.unesco.org/archive/2012/whc12-36com-8Ee.pdf

[5] UNESCO, “Angkor”, accessed on September 4, 2015, URL: http://whc.unesco.org/en/list/668

[6] APSARA Authority, “APSARA Authority: Number of Foreign Tourists to Angkor Increases Slightly in First Seven Months”, accessed on September 04, 2015, URL: http://www.cambodiatips.com/news/19153/apsara-authority:-number-of-foreign-tourists-to-angkor-increases-slightly-in-first-seven-months.html

[7] UNESCO, ‘‘World Heritage’’, accessed on September 10, 2015, URL: http://whc.unesco.org/archive/2012/whc12-36com-8Ee.pdf

ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់កិច្ចការពារ និងការអភិវឌ្ឍន៍ តំបន់ប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា (ICC-Angkor) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ដើម្បីធានាការសម្របសម្រួលគម្រោងជាបន្តបន្ទាប់តាមបែបវិទ្យាសាស្ត្រ ការស្តារឡើងវិញ និងការអភិរក្ស។[8] បន្ថែមពីនេះ កម្មវិធីជាច្រើនត្រូវបានបង្កើតឡើងដោយអង្គការយូណេស្កូ (UNESCO) ដើម្បីការពារតំបន់ដែលជានិមិត្តសញ្ញារបស់ប្រទេស និងតំបន់ដែលនៅជិតៗនោះ ដែលរួមមានច្បាប់ និងគោលនយោបាយការពារមួយចំនួន។ ដើម្បីបញ្ចៀសការបន្តបំផ្លិចបំផ្លាញទៅលើតំបន់បេតិកភ័ណ្ឌអង្គរ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រមួយ គឺបង្វែរទិសដៅអ្នកទេសចរណ៍ទៅតំបន់ទេសចរណ៍ដ៏ទៃទៀតនៅក្នុងប្រទេសដែលមានដូចជា ប្រាសាទដទៃទៀត ការលំហែកាយជាមួយនឹងអេកូធម្មជាតិ និងរមណីយដ្ឋានតាមមាត់សមុទ្រដែលទើបបង្កើតថ្មីៗ ជាដើម។[9]

បេតិកភ័ណ្ឌវប្បធម៌អរូបីនៅក្នុងប្រទេសកម្ពុជាអាចចែកចេញជាបីប្រភេទ៖ សិល្បៈសម្តែង (ការរាំ ខ្សែភាពយន្ត និងចម្រៀង) បេតិកភ័ណ្ឌវប្បធម៌តាមរយៈការនិយាយ(ភាសា) និងជំនាញផ្នែកសិល្បៈផ្សេងៗ។[10] ស្របតាមការវាយតម្លៃដំបូងនៃបេតិកភ័ណ្ឌវប្បធម៌អរូបីនៅក្នុងប្រទេសកម្ពុជា (First inventory of Cambodia’s intangible cultural heritage) ដែលបានបង្កើតនៅឆ្នាំ២០០៤ មានកត្តាជាច្រើនដែលធ្វើឲ្យបេតិកភ័ណ្ឌប្រភេទនេះប្រឈមទៅនឹងការខូចខាត ដូចជា ជម្លោះនយោបាយនិងឥទ្ធិពលវប្បធម៌ពីបរទេស។[11] ភាពចិតថេរនៃបេតិកភ័ណ្ឌវប្បធម៌នេះគឺដោយសារតែប្រពៃណីទំនៀមទំលាប់ខ្មែរ នៅតែដក់ជាប់នៅក្នុងនៅក្នុងដួងចិត្តរបស់ប្រជាជនខ្មែរតែប៉ុណ្ណោះ។[12]

---

[8] UNESCO, International Coordinating Committee for the Safeguarding and Development of the Historic Site of Angkor (ICC-Angkor), accessed on September 4, 2015, URL: http://www.unesco.org/new/en/phnompenh/culture/tangible-heritage/icc-angkor/

[9] World Archaeology, “Angkor Wat: Temple of Boom”, accessed on September 4, 2015, URL: http://www.world-archaeology.com/features/angkor-wat-temple-of-boom.htm

[10] *Intangible Cultural Heritage*, available at http://www.ichcap.org/kor/ek/sub1/pdf_file/south_east_asia/Cambodia_2009_02_Intangible_Cultural_Heritage_Inventory.pdf.

[11] UNESCO, *Intangible Heritage* (Phnom Penh,: UNESCO), available at: http://www.unesco.org/new/en/phnompenh/culture/intangible-heritage/.

[12] *Intangible Cultural Heritage*, available at http://www.ichcap.org/kor/ek/sub1/pdf_file/south_east_asia/Cambodia_2009_02_Intangible_Cultural_Heritage_Inventory.pdf.

## កិច្ចការពារប្រឆាំងនឹងការបំផ្លាញ និងការធ្វើឲ្យធ្លាក់ចុះនៃបេតិកភ័ណ្ឌរូបី និងអរូបីរបស់មនុស្សជាតិ

យុទ្ធសាស្ត្រដ៏ល្អមួយដើម្បីការពារបេតិកភ័ណ្ឌរូបី និងអរូបី គឺការកើនឡើងនូវការស្នាក់នៅតាម ផ្ទះប្រជាជន (homestay)។ គំនិតនេះត្រូវបានផ្តួចផ្តើមឡើងដើម្បីផ្តល់ដល់ភ្ញៀវទេសចរណ៍នូវបទពិសោធន៏ដែលប្លែក និងកាន់តែមានន័យ ព្រោះថាការស្នាក់នៅនេះនឹងធ្វើឲ្យអ្នកទេសចរណ៍ស្គាល់ពីជីវភាពរស់នៅរបស់ប្រជាជន នៅក្នុងតំបន់ និងវប្បធម៌ក្នុងការរស់នៅរបស់ពួកគេ។[13]

ការជួញដូរវត្ថុបុរាណខុសច្បាប់អាចមានការពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋហិង្សា និងភេរវកម្ម។[14] ក្តីអាម៉ាស់មួយដែលពាក់ព័ន្ធទៅនឹងការលួចយកវត្ថុបុរាណនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាគឺសកម្មភាព របស់បណ្តាញឧក្រិដ្ឋកម្មឆ្លងដែនពាក់ព័ន្ធនឹងការយកវត្ថុបុរាណចេញពីប្រាសាទបន្ទាយឆ្មារនៅឆ្នាំ១៩៩៨ និង នៅតាមតំបន់ប្រាសាទផ្សេងៗទៀត។[15] ក្នុងអំឡុងពីឆ្នាំ១៩៨៨ រហូតដល់ឆ្នាំ២០១០ វត្ថុបុរាណខ្មែរដែលត្រូវ បានជួញដូរទៅក្រៅប្រទេសមានចំនួនប្រហែល៣៧៧ (ក្នុងនោះ៧១% មិនមានចុះបញ្ជី និងមានតែ២៩% ប៉ុណ្ណោះ ដែលមានឯកសារបញ្ជាក់ពីប្រវត្តិកាន់កាប់)។ បញ្ហានេះបានបង្កើតអោយមានកង្វល់ខ្លាំងជាងមុនទៅលើមធ្យោបាយរបស់ប្រទេសដែលជាម្ចាស់ក្នុងការទាមទារមកវិញនូវវត្ថុបុរាណដែលបាត់បង់ខុសច្បាប់ និងរកមធ្យោបាយដើម្បីរកប្រាក់ដែលចំណេញបានមកពីការជួញដូរខុសច្បាប់នូវវត្ថុបុរាណទាំងនោះត្រលប់មកវិញ។[16]
នេះគឺជាក្តីបារម្ភណ៍ដ៏ធំមួយប្រសិនបើប្រាក់ដែលប្រមូលបានពីការជួញដូរនោះត្រូវបានប្រើប្រាស់ដើម្បី គាំទ្រសកម្មភាពភេរវកម្មនានាដូចជាមានឃើញនៅក្នុងព្រឹត្តការណ៍ថ្មីៗនេះ ដែលមានការបំផ្លាញរូបសំណាក់ និងវត្ថុបុរាណពីសំណាក់ក្រុម Assyrian និងក្រុម Akkadian ដែលជាក្តីកង្វល់រួមមួយរបស់សហគមន៍អន្តរជាតិ។[17]
វិបត្តិសកលលោកទាក់ទងនឹងវប្បធម៌នេះទាក់ទងទៅនឹងការលួច ការជួញដូរ និងការបំផ្លាញឥតឈប់ឈរទៅលើបេតិកភ័ណ្ឌវប្បធម៌ មិនថាតាមច្រកផ្លូវការឬមិនផ្លូវការ គឺសុទ្ធតែនាំមកនូវឥទ្ធិពលអាក្រក់ ទៅដល់សេដ្ឋកិច្ចសកល សុខមាលភាពវប្បធម៌ និងសន្តិសុខជាតិ(សូមមើលឧបសម្ព័ន្ធ១)។[18] ដើម្បីប្រឆាំងនឹង

---

[13] Ministry of Tourism in Cambodia, *Homestay in Cambodia*, available at http://www.tourismcambodia.com/activities/homestay-in-cambodia.htm.
[14] National Geographic, ''New Evidence Ties Illegal Antiquities Trade to Terrorism, Violent Crime'', accessed on September 14, 2015, URL: http://news.nationalgeographic.com/news/2014/06/140613-looting-antiquities-archaeology-cambodia-trafficking-culture/
[15] Ibid.
[16] Davis, T., ''Supply and demand: exposing the illicit trade in Cambodian antiquities through a study of Sotheby's auction house'', Crime Law Social Change (2011), Volume 56, Issue 2, p. 155-174
[17] The Guardian, "Isis fighters destroy ancient artefacts at Mosul museum", accessed September 04, 2015 URL: http://www.theguardian.com/world/2015/feb/26/isis-fighters-destroy-ancient-artefacts-mosul-museum-iraq
[18] The Cairo Declaration, 2015

និន្នាការនេះ ប្រទេសចំនួន១០ (អេហ្ស៊ីប អារ៉ាប៊ីសាអូឌី អារ៉ាប់អេមីរ៉ាត អ៊ីរ៉ាក់ ហ្សដង់ គុយវ៉ែត លីបង់ លីប៊ី ស៊ូដង់ និងអូម៉ង់) បានធ្វើការឯកភាពគ្នាចុះហត្ថលេខានៅខែឧសភា ឆ្នាំ២០១៥ ទៅលើសេចក្តីថ្លែង-ការណ៍គែរ (Cairo Declaration) ដើម្បីរារាំងមិនឲ្យមានការលួចយកវត្ថុបុរាណនៅក្នុងតំបន់មជ្ឈឹមបូព៌ា។ សេចក្តីប្រកាសនេះរួមបញ្ចូលនូវផែនការសកម្មភាពរួមថ្នាក់តំបន់មួយដែលមានចែងអំពីការងារមួយចំនួន ដូចជា៖

- ការបង្កើតក្រុមការងារជាន់ខ្ពស់ ហៅថាក្រុមការងារមជ្ឈឹមបូព៌ា និងអាហ្វ្រិកខាងជើង ហៅកាត់ថា MENA (Middle East and Northern Africa) ដើម្បីសម្របសម្រួលលើកិច្ចខិតខំប្រឹងប្រែងថ្នាក់តំបន់ និងអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរទុច្ចរិតលើសម្បត្តិវប្បធម៌
- ការបង្កើតក្រុមប្រឹក្សាទីប្រឹក្សាអន្តរជាតិ ដែលផ្តល់ការគាំទ្រដល់ក្រុមការងារស្នូលខាងលើ
- ផ្តួចផ្តើមឲ្យមានការចរចារក្នុងការចុះអនុស្សារណៈយោគយល់លើសម្បត្តិវប្បធម៌ថ្នាក់តំបន់ជាមួយនឹងប្រទេសនានា
- រៀបចំយុទ្ធនាការជាតិ និងអន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើចោរកម្ម ការជួញដូរ និងទីផ្សារងងឹត (នៃសម្បត្តិវប្បធម៌)
- បង្កើតឲ្យមានមជ្ឈមណ្ឌលឯករាជ្យ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរវត្ថុបុរាណខុសច្បាប់ (antiquities laundering)[19]។

ដើម្បីរក្សាឲ្យបាននូវបេតិកភ័ណ្ឌវប្បធម៌រូបី និងអរូបីនៃមនុស្សជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ បទបញ្ញត្តិ និងច្បាប់មួយចំនួនដូចជា៖

- ព្រះរាជក្រឹត្យស្តីពី ការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាបអង្គរត្រូវបានឡាយព្រះហស្ថលេខា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤។
- ច្បាប់ស្តីពី ការការពារបេតិកភ័ណ្ឌ វប្បធម៌ និងធម្មជាតិ ត្រូវបានប្រកាសឲ្យប្រើប្រាស់ចាប់តាំងពីថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦
- ព្រះរាជក្រឹត្យស្តីពី ការបង្កើតអាជ្ញាធរជាតិអប្សរា ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរដែលត្រូវបានឡាយព្រះហស្ថលេខាកាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤។ ព្រះរាជក្រឹត្យនេះអមដោយ៖

[19] Ibid.

- ផែនការគ្រប់គ្រងអង្គរ (The Angkor Management Plan-AMP) ដើម្បីរៀបចំកែប្រែរចនាសម្ព័ន្ធ និងពង្រឹងអាជ្ញាធរជាតិអប្សរា
- គម្រោងការចូលរួមអភិវឌ្ឍន៍សហគមន៍ (The Community Development Participation Project-CDPP) ដើម្បីរៀបចំការប្រើប្រាស់ដីធ្លី និងដើម្បីលើកទឹកចិត្តការចូលរួមពីសហគមន៍ក្នុងគោលបំណងបង្កើនប្រាក់ចំណូលបន្ថែមដល់សហគមន៍
- ក្របខ័ណ្ឌគ្រប់គ្រងបេតិកភ័ណ្ឌ (The Heritage Management Framework) ដើម្បីអភិរក្សបរិស្ថានជុំវិញតំបន់អង្គរ។ ក្របខ័ណ្ឌនេះរួមបញ្ចូលនូវផែនការគ្រប់គ្រងទេសចរណ៍ (Tourism Management Plan) និងកម្រិតនៃហានិភ័យ (Risk Map) និងធនធានធម្មជាតិ ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាលអូស្រ្តាលី និងអង្គការយូណេស្កូ (UNESCO)។

- អនុក្រឹត្យលេខ ៥០អនក/បក ស្តីពី ការរៀបចំ និងដំណើរការនៃអាជ្ញាធរអប្សរា ត្រូវបានឡាយព្រះហស្ថលេខាកាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨។
- អង្គភាពស៊ើបអង្កេតសាធារណៈ (The Pubic Investigation Unit) ត្រូវបានបង្កើតឡើងដើម្បីសិក្សាអំពីការទាមទារ និងការរំពឹងទុករបស់អ្នកទេសចរណ៍ ក៏ដូចជាដើម្បីត្រួតពិនិត្យមើលអត្តចរឹកអ្នកទេសចរណ៍ ដើម្បីធានាថាការគ្រប់គ្រង និងគោលនយោបាយច្បាស់លាស់នានាអាចឆ្លើយតបនឹងបញ្ហាទាំងនោះ។
- បេតិកភ័ណ្ឌវប្បធម៌អរូបី ត្រូវបានផ្សារភ្ជាប់នឹងបេតិកភ័ណ្ឌរូបី ដូចជាអង្គរវត្តជាដើម ដើម្បីការពារជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ដោយផ្តល់នូវការអភិវឌ្ឍន៍ក្នុងតំបន់ និងរក្សាប្រពៃណីបុរាណព្រមទាំងទំនៀមទម្លាប់វប្បធម៌ ដែលអនុវត្តកន្លងមក[20]។
- អនុសញ្ញារវាងអង្គការយូណេស្កូ និងកម្ពុជាសម្រាប់ការអភិរក្សបេតិកភ័ណ្ឌវប្បធម៌អរូបី ត្រូវបានទទួលសច្ចាប័នក្នុងឆ្នាំ ២០០៣ ដើម្បីអភិរក្សបេតិកភ័ណ្ឌអរូបីសម្រាប់អ្នកជំនាន់ក្រោយ។[21]

---

[20] World Heritage Committee, *Convention Concerning the Protection of the World Cultural and Natural Heritage* (UNESCO, Paris, 2012) , 91-92.

[21] UNESCO, *Intangible Heritage* (Phnom Penh,: UNESCO), available at: http://www.unesco.org/new/en/phnompenh/culture/intangible-heritage/.

## សេចក្តីសន្និដ្ឋាន និងកំណត់សម្គាល់ទៅលើជម្រើសគោលនយោបាយ

ឧបសគ្គចម្បងមួយក្នុងការការពារសម្បត្តិវប្បធម៌រូបី និងអរូបីនៅក្នុងប្រទេសកម្ពុជាគឺការកើនឡើងនូវចំនួនភ្ញៀវទេសចរណ៍ដែលមកទស្សនាប្រាសាទអង្គរវត្ត។ ការកើនឡើងដ៏ច្រើននេះ បានឈានទៅដល់ការបំផ្លាញវត្ថុបុរាណដែលមិនអាចជួសជុល និងជំនួសបាន។ ទោះបីជាយ៉ាងណាក៏ដោយ មានគោលនយោបាយ និងច្បាប់ជាច្រើននៅក្នុងកិច្ចការពារ និងការអនុញ្ញាតឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចក្រោយពីការបង្កើតឲ្យមានគណៈកម្មាធិការថែរក្សា និងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអង្គរ (ICC-Angkor) នៅក្នុងឆ្នាំ១៩៩៣។ ការបង្កើតនេះមានគោលដៅដើម្បីសម្របសម្រួលការស្រាវជ្រាវវិទ្យាសាស្ត្រ ការស្តារឡើងវិញ និងការអភិរក្សសម្បត្តិវប្បធម៌រូបី និងអរូបីទាំងនេះ។

ការគំរាមកំហែងមួយទៀតដែលបំផ្លាញនូវទីតាំងសម្បត្តិវប្បធម៌នៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោកនោះគឺ ការលួច និងការធ្វើអាជីវកម្មទៅលើវត្ថុបុរាណ។ ដើម្បីការពារអំពើខុសច្បាប់ទាំងនេះមិនឲ្យកើតមាននៅពេលអនាគត ប្រទេសនានាត្រូវធ្វើកិច្ចសហការគ្នាដូចជា ការបង្កើតនូវកម្លាំងមានសមត្ថកិច្ចជាមួយក្រុមប្រឹក្សាផ្តល់យោបល់ នៅក្នុងការឃ្លាំមើលការងារនៅថ្នាក់តំបន់ និងនៅថ្នាក់អន្តរជាតិ ដើម្បីប្រឆាំងទៅនឹងបទល្មើសទាំងនោះ បង្កើតនូវការចរចារ និងការសហការថ្នាក់តំបន់ និងការដាក់នូវយុទ្ធនាការថ្នាក់តំបន់ និងអន្តរជាតិដោយលើកកម្ពស់ការយល់ដឹងអំពីបញ្ហានេះ បន្ទាប់មកចុងក្រោយគឺការបង្កើតនូវមជ្ឈមណ្ឌលឯករាជ្យដើម្បីប្រឆាំងទៅនឹងបទល្មើសទាក់ទងនឹងវត្ថុបុរាណដែលជាផែនការណ៍សកម្មភាពយ៉ាងសំខាន់នៅក្នុងការការពារការបំផ្លាញនៅពេលអនាគត។

ដើម្បីពង្រឹងនូវកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌រូបី និងអរូបី សភានៃព្រះរាជាណាចក្រកម្ពុជាអាចពិចារណា និងលើកយកជម្រើសគោលនយោបាយ មួយចំនួនដូចខាងក្រោម ដើម្បីយកទៅពិចារណាលើកឡើងនៅក្នុងកិច្ចពិភាក្សា កិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភាលើកទី១៣៣ ខាងមុខនេះ ៖

- ជួចផ្តើម និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសក្នុងសហគមន៍អាស៊ាន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរបេតិកភ័ណ្ឌវប្បធម៌រូបីខុសច្បាប់ និងការពារទប់ស្កាត់នូវការបំផ្លិចបំផ្លាញបេតិកភ័ណ្ឌវប្បធម៌រូបីទាំងអស់នៅក្នុងតំបន់ ដោយៈ
  - ពង្រឹងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការជួញដូរបេតិកភ័ណ្ឌវប្បធម៌រូបីខុសច្បាប់ ដើម្បីបង្ការនូវការលួចយកវត្ថុបុរាណនានាលក់ទៅក្រៅប្រទេស

    - ធ្វើការចរចារទាមទារឲ្យមានការបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ នូវបេតិកភ័ណ្ឌវប្បធម៌រូបី ដែលបានបាត់បង់ តាមរយៈការជួញដូរខុសច្បាប់
- ក្នុងនាមជាសមាជិកនៃសហគមន៍អាស៊ាន សភានៃព្រះរាជាណាចក្រកម្ពុជាអាចផ្តួចផ្តើមឲ្យមានការចរចារដើម្បីចុះអនុស្សារណៈយោគយល់ពាក់ព័ន្ធនឹងបេតិកភ័ណ្ឌវប្បធម៌រូបីនិងអរូបី ជាមួយបណ្តាប្រទេសជាសមាជិកនៃសហភាពអន្តរសភាដទៃទៀត
- លើកកម្ពស់បេតិកភ័ណ្ឌវប្បធម៌អរូបីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការរៀបចំយុទ្ធនាការផ្សព្វ-ផ្សាយជាតិ និងអន្តរជាតិ
- ការពារ និងថែរក្សាភាសា ជាពិសេសភាសារបស់ជនជាតិដើមភាគតិច ដើម្បីរក្សាអត្តសញ្ញាណ និងវប្បធម៌ជាតិ[22]
- បង្កើតមូលនិធិបេតិកភ័ណ្ឌ ដើម្បីសម្របសម្រួលការស្រាវជ្រាវរុករកវត្ថុបុរាណមានតម្លៃរបស់ក្រុមការងារផ្នែកបុរាណវិទ្យា[23]
- ផ្តួចផ្តើម និងសហប្រតិបត្តិការបង្កើតបណ្តាញយន្តការទទួលពាក្យបណ្តឹង ដែលសភាទាំងឡាយជាសមាជិកអាចចែកចាយ និងទទួលព័ត៌មាន ពាក់ព័ន្ធនឹងការជួញដូរបេតិកភ័ណ្ឌវប្បធម៌រូបីខុស-ច្បាប់ ទាំងនៅក្នុងតំបន់ និងអន្តរជាតិ ដើម្បីងាយស្រួលក្នុងការចាត់វិធានការទប់ស្កាត់នូវបទ-ល្មើសខុសច្បាប់ទាំងអស់នោះ
- សភានៃព្រះរាជាណាចក្រកម្ពុជា អាចផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធនឹងបេតិកភ័ណ្ឌវប្បធម៌រូបី និងអរូបី ជាមួយបណ្តាប្រទេសជាសមាជិកសហភាពអន្តរសភា ដើម្បីកំណត់នូវបញ្ហាប្រឈម និងចូលរួមពិភាក្សារកដំណោះស្រាយរាល់បញ្ហាដែលកើតមានឡើង នៅក្នុងមហាសន្និបាតសហភាពអន្តរសភា ។

---

[22] UN News Centre, *Protection of minority languages is a human rights obligation* (2013), available on http://www.un.org/apps/news/story.asp?NewsID=44352#.VhN-_uyqqko.

[23] Archaeological Institute of America, *Outside Funding Opportunities*, available on https://www.archaeological.org/sitepreservation/outsidefunding.

# ឯកសារយោង


APSARA Authority, "APSARA Authority: Number of Foreign Tourists to Angkor Increases Slightly in First Seven Months", accessed on September 04, 2015, URL:

http://www.cambodiatips.com/news/19153/apsara-authority:-number-of-foreign-tourists-to-angkor-increases-slightly-in-first-seven-months.html

Archaeological Institute of America, *Outside Funding Opportunities*, available on https://www.archaeological.org/sitepreservation/outsidefunding.

Free Content Web, "UNESCO's Intangible Cultural Heritage Policies and Globalization", accessed September 10, 2015, URL: http://www.freecontentweb.com/content/unesco%E2%80%99s-intangible-cultural-heritage-policies-and-globalization

Nrodo et al. *Cultural Heritage and the Law*. 2009. p.15, accessed September 10, 2015, URL: http://www.iccrom.org/ifrcdn/pdf/ICCROM_ICS08_CulturalHeritageandLaw_en.pdf

UN News Centre, *Protection of minority languages is a human rights obligation* (2013), available on http://www.un.org/apps/news/story.asp?NewsID=44352#.VhN-_uyqqko.

UNESCO, ''Tangible Cultural Heritage'', accessed on September 1, 2015, URL: http://www.unesco.org/new/en/cairo/culture/tangible-cultural-heritage/

UNESCO, ''What is Intangible Cultural Heritage'', accessed on September 1, 2015, URL: http://www.unesco.org/culture/ich/index.php?pg=00002http://www.unesco.org/culture/ich/index.php?pg=00002

UNESCO, "Angkor", accessed on September 4, 2015, URL: http://whc.unesco.org/en/list/668

UNESCO, International Coordinating Committee for the Safeguarding and Development of the Historic Site of Angkor (ICC-Angkor), accessed on September 4, 2015, URL: http://www.unesco.org/new/en/phnompenh/culture/tangible-heritage/icc-angkor/

The Guardian, "Isis fighters destroy ancient artefacts at Mosul museum", accessed September 04, 2015 URL: http://www.theguardian.com/world/2015/feb/26/isis-fighters-destroy-ancient-artefacts-mosul-museum-iraq

World Archaeology, "Angkor Wat: Temple of Boom", accessed on September 4, 2015, URL: http://www.world-archaeology.com/features/angkor-wat-temple-of-boom.htm

# ឧបសម្ព័ន្ធ

Annex I: The Global Crisis of Cultural Racketeering




Source: the Antiquities Coalition, http://www.theantiquitiescoalition.org/infographics/